ORAQUICK®
HIV SELF-TEST

www.oraquickhivselftest.com
សេចក្ដីណែនាំ

# ការណែនាំពីរបៀបធ្វើតេស្ដ

**អ្នកត្រូវតែអនុវត្តតាមការណែនាំពីរបៀបធ្វើតេស្ដដោយប្រុងប្រយ័ត្នដើម្បីទទួលបានលទ្ធផលតេស្ដត្រឹមត្រូវ។** កុំពិសារឬផឹកទឹកអ្វីយ៉ាងហោចណាស់ ១៥ នាទី ឬហាម ប្រើផលិតផលសម្អាតមាត់ ៣០ នាទីមុនពេលអ្នកចាប់ផ្ដើមធ្វើតេស្ដ។

**បម្រាមៈ ប្រសិនបើអ្នកកំពុងប្រើឱសថប្រឆាំងមេរោគអេដស៍ (ARV) លទ្ធផលតេស្ដរបស់អ្នកអាចនឹងមិនត្រឹមត្រូវ។**

## របៀបប្រើប្រាស់កញ្ចប់ ORAQUICK® ដើម្បីធ្វើតេស្ដរកមេរោគអេដស៍ដោយខ្លួនឯង

1




**អ្នកត្រូវមានឧបករណ៍សម្រាប់កំណត់ពេលវេលាក្នុងការធ្វើតេស្ដ**

2



កញ្ចប់តេស្ដមានៈ
ឧបករណ៍សម្រាប់ធ្វើតេស្ដ ជើងទម្រ
និងការណែនាំពីរបៀបប្រើប្រាស់

3



ក្នុងកញ្ចប់តេស្ដចែកចេញជា២

4



ហែកកញ្ចប់ដែលមាន**បំពង់នៅខាងក្នុង**

5



បើកគម្រប**បំពង់**ចេញ

6



**មិនត្រូវ**ចាក់ទឹកក្នុង**បំពង់**ចោល
ឬ ផឹកវាទេ

7



ដាក់**បំពង់បញ្ឈរ** នៅលើ**ជើងទម្រ**

8




ហែកកញ្ចប់ដែលមាន**ឧបករណ៍សម្រាប់ធ្វើតេស្ដ**រួចយកវាចេញ។
**មិនត្រូវ**ប៉ះផ្នែករាបស្មើនៅខាងចុងឧបករណ៍តេស្ដឡើយ។
**មិនត្រូវ**ពិសារឬលេបកញ្ចប់ស្រូបសំណើមនោះទេ។

9




(រូបទី ១) ដាក់ផ្នែកនៃ**បន្ទះរាបស្មើ**សង្កត់លើអញ្ចាញធ្មេញខាងលើរបស់អ្នកហើយអូសវាតាម**អញ្ចាញធ្មេញមួយដង។**
(រូបទី ២) បន្ទាប់មក**អូសតាមអញ្ចាញធ្មេញខាងក្រោមរបស់អ្នកមួយដងដែរ ។**

10



ដាក់**បន្ទះ**ផ្នែក**រាបស្មើ**
ចូលទៅក្នុង**បំពង់**រហូតដល់បាត

11




**រង់ចាំរយៈពេល ២០ នាទីមុនពេលមើលលទ្ធផលតេស្ដ។ មិនត្រូវមើលលទ្ធផលតេស្ដ**ក្រោយរយៈពេល៤០នាទី។

## ការបកស្រាយលទ្ធផល មើលលទ្ធផលតេស្ដនៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់

### លទ្ធផលតេស្ដ វិជ្ជមាន




មានបន្ទាត់ឆ្នូត២
ទោះបីជាមានបន្ទាត់១មិនសូវជិតច្បាស់ក៏ដោយ
ក៏លទ្ធផលតេស្ដរបស់អ្នកវិជ្ជមានដែរ ។
ដូច្នេះអ្នកត្រូវតែទៅរកកន្លែងធ្វើ
តេស្ដបញ្ជាក់បន្ថែមទៀត។

**លឿនបំផុតតាមដែលអាចធ្វើបាន ...**

**ទៅរក**សេវាធ្វើតេស្ដរកមេរោគអេដស៍
**ឬនៅតាមសេវាសុខភាពដែលនៅជិតអ្នកបំផុត**

### លទ្ធផលតេស្ដអវិជ្ជមាន

**ប្រសិនបើមើលលទ្ធផលតេស្ដមុនរយៈពេល ២០ នាទី នោះលទ្ធផលតេស្ដអាចនឹងមិនត្រឹមត្រូវ**




មានបន្ទាត់ឆ្នូត១ នៅចំណុច "C"
ហើយគ្មានបន្ទាត់ឆ្នូត១ទៀតនៅចំណុច "T"
នោះលទ្ធផលតេស្ដរបស់អ្នក គឺអវិជ្ជមាន។

រកធ្វើតេស្ដជាប្រចាំ។ ប្រសិនបើអ្នក
អាចនឹងប្រឈមនឹងមេរោគអេដស៍ HIV
ធ្វើតេស្ដម្ដងទៀតក្នុងរយៈពេល 3 ខែ។

### លទ្ធផលតេស្ដមិនត្រឹមត្រូវ




គ្មានបន្ទាត់ឆ្នូតនៅចំណុច "C"
(ទោះបីជាមានបន្ទាត់ឆ្នូតនៅចំណុច "T")
ឬក៏មានផ្ទៃពណ៌ក្រហមពេញ ដែលមិនអាចមើល
លទ្ធផលបានក៏ដោយនោះមានន័យថាការធ្វើតេស្ដ
របស់អ្នកមិនដំណើការ។ ដូច្នេះអ្នកគួរតែទៅធ្វើតេស្ដ
ម្ដងទៀត។

**អ្នកនឹងត្រូវតែធ្វើតេស្ដម្ដងទៀត ។**

តេស្ដដំណើរការមិនត្រឹមត្រូវ។

ចូរទៅរកធ្វើតេស្ដម្ដងទៀតនៅសេវាដែលមានការធ្វើតេស្ដរកមេរោគ HIV អេដស៍ដែលនៅជិតអ្នកបំផុត។

### លទ្ធផលតេស្ដមិនច្បាស់លាស់

អ្នកមិនដឹង ឬមិនច្បាស់លាស់ ពីលទ្ធផលតេស្ដរបស់អ្នក។

ចូរទៅរកធ្វើតេស្ដម្ដងទៀតនៅសេវាដែលមានការធ្វើតេស្ដរកមេរោគ HIV អេដស៍ដែលនៅជិតអ្នកបំផុត។

### បោះចោល

ដកបន្ទះតេស្ដចេញពីបំពង់ រួចគ្របគម្របបំពង់ ហើយបោះឧបករណ៍ទាំងអស់ចោលទៅក្នុងធុងសំរាមធម្មតា។

**ប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវប៉ុណ្ណោះ មិនមែនសម្រាប់ការថែទាំអ្នកជំងឺទេ**

## ព័ត៌មានអំពីផលិតផល

**REF** 5X4-1000, 5X4-1001, 5X4-2001

**សម្រាប់ប្រើប្រាស់តែនៅក្រៅប្រទេសអាមេរិកតែប៉ុណ្ណោះ**
**ប្រើប្រាស់សំរាប់ធ្វើរោគវិនិច្ឆ័យ តេស្ត១ ប្រើប្រាស់បានតែម្តង**

### គោលបំណងក្នុងការប្រើប្រាស់

OraQuick® គឺជាឧបករណ៍ធ្វើរោគវិនិច្ឆ័យវេជ្ជសាស្រ្តរកមេរោគអេដស៍ដែលត្រូវបានគេប្រើសម្រាប់ធ្វើតេស្តដោយខ្លួនឯងរកអង្គបក្ខដិបក្ខប្រាណ HIV-1 និង HIV-2 ដែលមាននៅក្នុងទឹកមាត់មនុស្ស។
តេស្តនេះគឺជាឧបករណ៍ជំនួយដើម្បីរកអង្គបក្ខដិបក្ខប្រាណ HIV-1 និង HIV-2 របស់បុគ្គលដែលបានឆ្លងមេរោគអេដស៍។

### សេចក្តីសង្ខេបនៃតេស្ត

OraQuick® ជាឧបករណ៍ធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង ដែលតេស្ត១ប្រើបានតែម្តងគត់ វាជាប្រភេទតេស្ត Qualitative Immunoassay រកអង្គបក្ខដិបក្ខប្រាណប្រឆាំងមេរោគអេដស៍ប្រភេទ HIV-1 និងប្រភេទ HIV-2 ដែលមាននៅក្នុងទឹកមាត់មនុស្ស ។ OraQuick® គឺជាឧបករណ៍ជំនួយក្នុងការធ្វើតេស្តដោយខ្លួនឯងសម្រាប់ធ្វើរោគវិនិច្ឆ័យនៃការឆ្លងមេរោគអេដស៍ប្រភេទ HIV-1 និងប្រភេទ HIV-2។ ការប្រើគឺគេដាក់ផ្នែកបន្ទះរាបស្មើទៅក្នុងមាត់តាមចន្លោះថ្គាល់ និងអញ្ចាញធ្មេញ រួចអូសតាមបណ្តោយអញ្ចាញធ្មេញខាងលើ១ដង និងខាងក្រោម១ដង។ បន្ទាប់មកយកឧបករណ៍តេស្តដាក់ចូលទៅក្នុងបំពង់ដែលមានល្បាយរាវ។ ទឹកមាត់ពីផ្នែកអញ្ចាញធ្មេញជ្រាបចូលទៅក្នុងឧបករណ៍តេស្តតាមរយៈបន្ទះរាបស្មើ ហើយជ្រាបចូលទៅក្នុងឧបករណ៍តេស្ត។ នៅពេលដែលវាហូរកាត់ឧបករណ៍តេស្ត វាលេចចេញជាបន្ទាត់ឆ្នូតពណ៌នៅចំណុច "T" (តេស្ត) ប្រសិនបើអង្គបក្ខដិបក្ខប្រាណមេរោគអេដស៍ត្រូវបានរកឃើញ។ ប្រសិនបើគ្មានអង្គបក្ខដិបក្ខប្រាណមេរោគអេដស៍ទេ នោះក៏គ្មានលេចចេញបន្ទាត់ឆ្នូតពណ៌នៅចំណុចនោះដែរ។ ប្រសិនបើតេស្តបានធ្វើឡើងដោយត្រឹមត្រូវ គឺមានលេចបន្ទាត់ឆ្នូតពណ៌ឡើងនៅក្នុងចំណុច "C" ជាកន្លែងដែលបង្ហាញលទ្ធផល។ នេះគេហៅថាបន្ទាត់ត្រួតពិនិត្យ។

### ការធ្វើតេស្ត

ក្នុងការសិក្សាបែបគ្លីនិកមួយលើមនុស្ស ៩០០ នាក់ដែលមិនដឹងពីស្ថានភាពមេរោគអេដស៍ត្រូវបានគេធ្វើតេស្តដោយប្រើឧបករណ៍ធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង OraQuick® ។ លទ្ធផលត្រូវបានប្រៀបធៀបជាមួយនឹងតេស្តនៅមន្ទីរពិសោធន៍ជំនាន់ទី ៤។ លទ្ធផលតេស្តមន្ទីរពិសោធន៍បង្ហាញថាមនុស្សចំនួន ១៥៣ នាក់គឺមានលទ្ធផលតេស្តរកមេរោគអេដស៍វិជ្ជមាន និងមាន ៧២៤ នាក់មានលទ្ធផលតេស្ត អវិជ្ជមាន។ មនុស្សចំនួន៧នាក់ត្រូវបានដកចេញពីការសិក្សាស្រាវជ្រាវ។ ការប្រៀបធៀបលទ្ធផលមានដូចខាងក្រោម៖

- ៩៩.៤ភាគរយ នៃមនុស្សទាំងអស់ (១៥២ នាក់ក្នុងចំណោម ១៥៣ នាក់) បានរាយការណ៍យ៉ាងត្រឹមត្រូវថាលទ្ធផលតេស្តរបស់ពួកគេគឺវិជ្ជមាន។ នេះមានន័យថា១នាក់ ក្នុងចំណោម១៥៣នាក់ ដែលបានឆ្លងមេរោគអេដស៍ តែបានរាយការណ៍ថាលទ្ធផលតេស្តអវិជ្ជមាន។ នេះគឺហៅថាអវិជ្ជមានមិនពិត។
- ៩៩.0ភាគរយ នៃមនុស្សទាំងអស់ (៧១៧នាក់ក្នុងចំណោម ៧២៤នាក់) បានរាយការណ៍យ៉ាងត្រឹមត្រូវថាលទ្ធផលរបស់ពួកគេគឺអវិជ្ជមាន។ នេះមានន័យថាមនុស្ស៧ នាក់ ក្នុងចំណោមមនុស្ស៧២៤ នាក់មិនបានឆ្លងមេរោគអេដស៍ តែបានរាយការណ៍ថាលទ្ធផលនៃ តេស្តវិជ្ជមាន។ នេះគឺហៅថាវិជ្ជមានមិនពិត។
- បន្ថែមពីនេះទៀត មានត្រឹមតែ 1.8% នៃប្រធានបទស្រាវជ្រាវ (16 នាក់ក្នុងចំណោម 900 នាក់) មិនអាចទទួលបានលទ្ធផលនៃការធ្វើតេស្ត។




### ឧបករណ៍ដែលមាននៅក្នុងកញ្ចប់

- ក្នុងកញ្ចប់ឧបករណ៍មួយមាន៖
  - កញ្ចប់ (5X4-0004) មានឧបករណ៍តេស្ត១ ដែលប្រើបានតែម្តង មានកញ្ចប់ស្រូបសំណើម១ និងបំពង់ល្បាយទឹកថ្នាំ១
  - ជើងទម្រ
  - ការណែនាំពីរបៀបប្រើប្រាស់
- សម្ភារដែលត្រូវការចាំបាច់ ប៉ុន្តែមិនបានផ្តល់ឲ្យ៖ នាឡិកា ឬឧបករណ៍កំណត់ពេលវេលា

### ⚠ បំរាម និងការប្រុងប្រយ័ត្ន

- មនុស្សភាគច្រើនមានអារម្មណ៍ភ័យខ្លាចនៅពេលធ្វើតេស្តរកមេរោគអេដស៍។ បើអ្នកមានអារម្មណ៍ភ័យខ្លាំងចំពោះការធ្វើតេស្ត អ្នកអាចនឹងត្រូវការពេលវេលារហូតមានអារម្មណ៍ស្ងប់ដើម្បីធ្វើតេស្ត ឬអាចទៅធ្វើតេស្តដោយគ្រូពេទ្យ ឬនៅគ្លីនិកនៅក្នុងតំបន់ ។
- មិនត្រូវធ្វើតេស្ត ប្រសិនបើអ្នកបានដឹងថាអ្នកមានផ្ទុកមេរោគអេដស៍រួចហើយ។
- ប្រើបានតែជាមួយទឹកមាត់ប៉ុណ្ណោះ។ តេស្តនេះមិនត្រូវប្រើជាមួយឈាម ស៊េរ៉ូម ទឹកដោះ ប្លាស្មា ទឹកកាម ទឹកនោម ទឹករំអិលទ្វារមាស ឬញើសនោះទេ។
- មិនត្រូវពិសារ ឬផឹកអ្វី យ៉ាងហោចណាស់ ១៥នាទី មុនពេលចាប់ផ្តើមធ្វើតេស្ត។
- មិនត្រូវប្រើផលិតផលសម្អាតមាត់ (ដូចជាទឹកខ្ពុរមាត់) ៣០ នាទីមុនពេលចាប់ផ្តើមធ្វើតេស្ត។
- ដកធ្មេញពាក់ ឬឧបករណ៍ដែលគ្របលើអញ្ចាញធ្មេញរបស់អ្នកចេញពីក្នុងមាត់មុនពេលយកទឹកមាត់។
- ប្រសិនបើកញ្ចប់ខ្ចប់ឧបករណ៍តេស្តហែក ឬដាច់ ឬ បើសិនមានបាត់ផ្នែកណាមួយ ឬបាក់បែក ឬបើកចំហរ មិនត្រូវប្រើឧបករណ៍តេស្តនេះទេ។
- ប្រសិនបើថ្ងៃដែលបើកកញ្ចប់ប្រើ វាហួសកាលកំណត់ការប្រើ សូមកុំប្រើកញ្ចប់តេស្តនេះ។
- ត្រូវមើលលទ្ធផលតេស្តនៅកន្លែងមានពន្លឺគ្រប់គ្រាន់។ ប្រសិនបើមានបន្ទាត់ឆ្នូត២លេចឡើងនៅចំណុច "T" និង "C" មិនថាមានកម្រិតដិតប៉ុណ្ណា លទ្ធត្រូវបានចាត់ទុកថាតេស្តវិជ្ជមាន។
- មិនត្រូវបើកកញ្ចប់ណាមួយទុកចោល លុះត្រាតែអ្នកបានត្រៀមខ្លួនរួចរាល់ក្នុងការចាប់ផ្តើមធ្វើតេស្ត។
- មិនត្រូវប្រើតេស្តនេះប្រសិនបើវា មានការប៉ះពាល់ទៅនឹងផលិតផលសម្អាតផ្ទះ (ឧ. ទឹកជូតសម្អាតផ្ទះ)។
- ប្រសិនបើអ្នកបានចូលរួមក្នុងការសាកល្បងប្រើវ៉ាក់សាំងការពារមេរោគអេដស៍ នោះលទ្ធតេស្តរបស់អ្នកអាចនឹងវិជ្ជមាន ប៉ុន្តែក៏មិនមានន័យថា អ្នកមានឆ្លងមេរោគអេដស៍នោះទេ។ អ្នកគួរតែទៅធ្វើតេស្តម្តងទៀតនៅសេវាដែលមានការធ្វើតេស្តរកមេរោគអេដស៍ ។
- មិនត្រូវប្រើតេស្តនេះប្រសិនបើអ្នកមានអាយុ១១ឆ្នាំ ឬក្មេងជាងនេះ។

### ការរក្សាទុក

30 °C – 2 °C

- រក្សាទុក និងធ្វើតេស្តនេះនៅកន្លែងត្រជាក់
- **មិន**ត្រូវប្រើតេស្តនេះប្រសិនបើវាត្រូវបានរក្សាទុកនៅក្រៅកន្លែងមានសីតុណ្ហភាពដែលអាចទទួលយកបានដែលចាប់ពី 2°-30° C (36°-86° F)។
- តេស្តគួរតែធ្វើនៅកន្លែងណាដែលមានសីតុណ្ហភាពចាប់ពី 15°-37° C (59°-99° F)។

### ដែនកំណត់នៃការប្រើប្រាស់តេស្ត

- ការណែនាំស្តីពីរបៀបប្រើប្រាស់កញ្ចប់ឧបករណ៍ធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង OraQuick® ត្រូវតែធ្វើតាមការណែនាំដោយប្រុងប្រយ័ត្នទើបទទួលលទ្ធផលតេស្តបានត្រឹមត្រូវ។
- ប្រសិនបើអ្នកកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ARVs) លទ្ធផលតេស្តរបស់អ្នកអាចនឹងមិនត្រឹមត្រូវ។
- ប្រសិនបើអ្នកមានផ្ទុកមេរោគលាកថ្លើមប្រភេទ បេ, សេ, ឬ មានផ្ទុកមេរោគ HTLV I/II អ្នកអាចទទួលលទ្ធផលតេស្តមិនត្រឹមត្រូវ។
- ការចេញឈាមនៅក្នុងមាត់ អាចធ្វើឲ្យលទ្ធផលតេស្តមិនអាចយកជាការបាន។ ប្រសិនបើលទ្ធផលតេស្តមិនអាចយកជាការបាន ចូរទៅរកធ្វើតេស្តម្តងទៀតនៅសេវាដែលមានការធ្វើតេស្តរកមេរោគអេដស៍ ដែលនៅជិតអ្នកបំផុត។
- ចំពោះបុគ្គលដែលកំពុងប្រើប្រាស់ឱសថបង្ការមុនពេលប្រឈមនឹងការឆ្លងមេរោគអេដស៍ (PrEP) ទិន្នន័យគ្លីនិកមិនបានប្រមូលយកមកបង្ហាញក្នុងការធ្វើ តេស្តរកមេរោគអេដស៍ដោយខ្លួនឯង OraQuick® នោះទេ។
- តេស្តរកមេរោគអេដស៍ដោយខ្លួនឯង OraQuick® អ្នកអាចនឹងរកមិនឃើញមេរោគអេដស៍នៅពេលអ្នកបានឆ្លងក្នុងកំឡុងពេលពេលបីខែមុន។
- សម្រាប់លទ្ធផលតេស្តវិជ្ជមាន ភាពដិតនៃបន្ទាត់ មិនចាំបាច់ស្មើនឹងបរិមាណអង្គបដិបក្ខប្រាណនៅក្នុងគំរូនោះទេ។
- លទ្ធផលវិជ្ជមាន គួរតែទៅធ្វើតេស្តបញ្ជាក់ផ្សេងទៀត ដែលធ្វើឡើងដោយអ្នកជំនាញដែលបានបណ្តុះបណ្តាល ដើម្បីបញ្ជាក់ក្នុងការធ្វើរោគវិនិច្ឆ័យរកមេរោគអេដស៍។

### សំនួរ -ចម្លើយ

1. ***តើតេស្តមានដំណើរការយ៉ាងដូចម្តេច ?***
   OraQuick® គឺជាឧបករណ៍ធ្វើរោគវិនិច្ឆ័យវេជ្ជសាស្រ្តរកមេរោគអេដស៍ដោយខ្លួនឯង។ វាត្រូវបានគេប្រើសម្រាប់ធ្វើតេស្តដោយខ្លួនឯងរកអង្គបក្ខដិបក្ខប្រាណ HIV-1 និង HIV-2 ដែលមាននៅក្នុងទឹកមាត់មនុស្ស។ តេស្តដំណើរការដោយរកអង្គបដិបក្ខប្រាណធម្មជាតិមាននៅក្នុងខ្លួនរបស់អ្នកដែលជួយប្រឆាំងនឹងមេរោគឆ្លង ។ លទ្ធផលវិជ្ជមាន គឺជាលទ្ធផលបឋម ដូច្នេះអ្នកត្រូវតែធ្វើតេស្តបញ្ជាក់បន្ថែមទៀតនៅសេវាសុខភាពដើម្បីបញ្ជាក់ថាលទ្ធផលតេស្តរបស់អ្នកគឺពិតប្រាកដ។
2. ***តើអ្វីជាការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ?***
   ការប្រព្រឹត្តប្រឈមមានដូចខាងក្រោម៖
   - ការរួមភេទ (ទ្វារមាស មាត់ ឬរន្ធគូថ) ជាមួយដៃគូរួមភេទច្រើននាក់និង ដោយមិនបានការពារ
   - ការរួមភេទជាមួយអ្នកផ្ទុកមេរោគអេដស៍ ឬជាមួយអ្នកដែលមិនដឹងពីស្ថានភាពនៃការផ្ទុកមេរោគអេដស៍
   - ការរួមភេទរវាងបុរសនិងបុរស
   - ការចាក់គ្រឿងញៀន ឬ ថ្នាំស្តេរ៉ូអ៊ីត
   - ប្រើម្ជុលឬសឺរ៉ាំងរួមគ្នា
   - ការរួមភេទដោយការដោះដូរយកប្រាក់ឬ អំណោយផ្សេងៗ
   - មានរោគវិនិច្ឆ័យ ឬព្យាបាលជំងឺរលាកថ្លើម ជំងឺរបេង ឬជំងឺកាមរោគដូចជាជំងឺស្វាយជាដើម
3. ***តើរយៈពេលឆាប់ប៉ុណ្ណា ទើបខ្ញុំអាចធ្វើតេស្តបានដោយខ្លួនឯង បន្ទាប់ពីខ្ញុំមានការប្រព្រឹត្តប្រឈម ?***
   អ្នកអាចធ្វើតេស្តបានគ្រប់ពេល។ ប្រសិនបើអ្នកធ្វើតេស្តនេះមុនពេល3ខែចាប់តាំងពីព្រឹត្តិការណ៍គ្រោះថ្នាក់ ហើយការធ្វើតេស្តរបស់អ្នកគឺអវិជ្ជមាន, លទ្ធផលរបស់អ្នកប្រហែលជាមិនត្រឹមត្រូវទេ។ អ្នកគួរតែធ្វើតេស្តម្តងទៀតនៅ 3 ខែក្រោយពីព្រឹត្តិការណ៍គ្រោះថ្នាក់ដើម្បីអោយប្រាកដ។ អ្នកក៏អាចធ្វើតេស្តនៅមណ្ឌលសុខភាពបានផងដែរ។
4. ***ហេតុអ្វីខ្ញុំមិនគួរធ្វើតេស្តនេះភ្លាមៗ បន្ទាប់ពីមានការប្រព្រឹត្តប្រឈម ?***
   នៅពេលអ្នកបានឆ្លងមេរោគអេដស៍ រាងកាយរបស់អ្នកព្យាយាមប្រយុទ្ធនឹងមេរោគអេដស៍ដោយផលិតអង្គបដិបក្ខប្រាណប្រឆាំងនឹងមេរោគ។ អង្គបដិបក្ខប្រាណអាចរកឃើញនៅក្នុងទឹកមាត់របស់អ្នក។ រាងកាយរបស់អ្នកត្រូវការរយៈពេលរហូត ៣ខែ ដើម្បីឲ្យរាងកាយរបស់អ្នកបង្កើតបានអង្គបដិបក្ខប្រាណទៅតាមកំរិតដែលអាចរកឃើញដោយតេស្តនេះ។
5. ***តើតេស្តនេះត្រឹមត្រូវប៉ុណ្ណា ?***
   ក្នុងការសិក្សាបែបគ្លីនិកមួយលើមនុស្ស ៩០០ នាក់ដែលមិនដឹងពីស្ថានភាពមេរោគអេដស៍ត្រូវបានគេធ្វើតេស្តដោយប្រើឧបករណ៍ធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង OraQuick® ។ លទ្ធផលត្រូវបានប្រៀបធៀបជាមួយនឹងតេស្តនៅមន្ទីរពិសោធន៍ជំនាន់ទី ៤។ លទ្ធផលតេស្តមន្ទីរពិសោធន៍បង្ហាញថាមនុស្សចំនួន ១៥៣ នាក់គឺមានលទ្ធផលតេស្តរកមេរោគអេដស៍វិជ្ជមាន និងមាន ៧២៤ នាក់មានលទ្ធផលតេស្ត អវិជ្ជមាន។ មនុស្សចំនួន៧នាក់ត្រូវបានដកចេញពីការសិក្សាស្រាវជ្រាវ។ ការប្រៀបធៀបលទ្ធផលមានដូចខាងក្រោម៖
   - ៩៩.៤ភាគរយ នៃមនុស្សទាំងអស់ (១៥២ នាក់ក្នុងចំណោម ១៥៣ នាក់) បានរាយការណ៍យ៉ាងត្រឹមត្រូវថាលទ្ធផលតេស្តរបស់ពួកគេគឺវិជ្ជមាន។ នេះមានន័យថា១នាក់ ក្នុងចំណោម១៥៣នាក់ ដែលបានឆ្លងមេរោគអេដស៍ តែបានរាយការណ៍ថាលទ្ធផលតេស្តអវិជ្ជមាន។ នេះគឺហៅថាអវិជ្ជមានមិនពិត។
   - ៩៩.0ភាគរយ នៃមនុស្សទាំងអស់ (៧១៧នាក់ក្នុងចំណោម ៧២៤នាក់) បានរាយការណ៍យ៉ាងត្រឹមត្រូវថាលទ្ធផលរបស់ពួកគេគឺអវិជ្ជមាន។ នេះមានន័យថាមនុស្ស៧ នាក់ ក្នុងចំណោមមនុស្ស៧២៤ នាក់មិនបានឆ្លងមេរោគអេដស៍ តែបានរាយការណ៍ថាលទ្ធផលនៃ តេស្តវិជ្ជមាន។ នេះគឺហៅថាវិជ្ជមានមិនពិត។
   - បន្ថែមពីនេះទៀត មានត្រឹមតែ១.៨ភាគរយ នៃប្រធានបទស្រាវជ្រាវ (១៦ នាក់ក្នុងចំណោម៩០០ នាក់) មិនអាចទទួលលទ្ធផលនៃការធ្វើតេស្ត។
6. ***តើខ្ញុំអាចឆ្លងមេរោគអេដស៍ ដោយការប្រើប្រាស់តេស្តនេះដែរឬទេ ?***
   តេស្តនេះមិនមានផ្ទុកសារធាតុ ឬមេរោគអេដស៍ដែលអាចបង្កឲ្យមានការឆ្លងមេរោគអេដស៍នោះទេ។
7. ***តើមនុស្សម្នាក់ៗគួរតែធ្វើតេស្តរកមេរោគអេដស៍ញឹកញាប់ប៉ុណ្ណា ?***
   ប្រសិនបើអ្នកមិនដែលបានធ្វើតេស្តរកមេរោគអេដស៍សោះ អ្នកគួរតែធ្វើតេស្តយ៉ាងហោចណាស់បានម្តង។ ប្រសិនបើអ្នកធ្វើអ្វី (ការប្រព្រឹត្តប្រឈម) ដែលអាចបង្កឲ្យមានការឆ្លងមេរោគអេដស៍ អ្នកគួរតែធ្វើតេស្តយ៉ាងហោចណាស់បានម្តងក្នុង១ឆ្នាំ (អនុសាសន៍របស់អង្គការសុខភាពពិភពលោក) ។
   **ប្រសិនបើអ្នកមានអារម្មណ៍ថាអ្នកប្រឈមខ្ពស់ក្នុងការឆ្លងមេរោគអេដស៍អ្នកគួរតែធ្វើតេស្តឲ្យបានទៀងទាត់រៀងរាល់៦ខែម្តង។**
8. ***តើលទ្ធផលតេស្តអវិជ្ជមានមានន័យយ៉ាងដូចម្តេច ?***
   លទ្ធផលតេស្តអវិជ្ជមាន មានន័យថាការធ្វើតេស្តរកមិនឃើញអង្គបដិបក្ខប្រាណណាមួយទេ ទោះជាយ៉ាងក្តីវាត្រូវការរយៈពេលរហូតដល់៣ខែបន្ទាប់ពីការប្រព្រឹត្តប្រឈមទើបអាចធ្វើតេស្តរកឃើញមេរោគអេដស៍។ ក្នុងកំឡុងពេលយ៉ាងតិច៣ ខែដែលអ្នកបានប្រព្រឹត្តប្រឈម ហើយបានអនុវត្តតាមការណែនាំរបៀបប្រើប្រាស់តេស្តដោយប្រុងប្រយ័ត្ន អ្នកទំនងជាមិនមានការឆ្លងមេរោគអេដស៍ទេ។ ប្រសិនបើអ្នកបានប្រព្រឹត្តប្រឈមតិចជាង៣ ខែ ហើយរង់ចាំរហូតដល់ ៣ ខែពេញ ដើម្បីធ្វើតេស្ត ឬទៅ ធ្វើតេស្តនៅសេវាសុខភាព ។
9. ***តើខ្ញុំគួរធ្វើដូចម្តេចប្រសិនបើខ្ញុំទទួលបានលទ្ធផលតេស្តអវិជ្ជមាន ?***
   ប្រសិនបើអ្នកមិនបានប្រព្រឹត្តប្រឈមក្នុងកំឡុងពេល៣ខែមុន ហើយអ្នកបានធ្វើតាមការណែនាំពីរបៀបប្រើប្រាស់តេស្តដោយប្រុងប្រយ័ត្ន នោះលទ្ធផលតេស្តរបស់អ្នកទំនងជាអវិជ្ជមាន ។ ប្រសិនបើអ្នកមិនបានអនុវត្តតាមការណែនាំពីរបៀបប្រើប្រាស់ដោយប្រុងប្រយ័ត្នទេ អ្នកគួរតែធ្វើតេស្តម្តងទៀតដើម្បីឲ្យប្រាកដថាលទ្ធផលតេស្តរបស់អ្នកគឺត្រឹមត្រូវ។ ប្រសិនបើអ្នកបានប្រព្រឹត្តប្រឈម កាលពី ៣ខែមុន អ្នកអាចនឹងស្ថិតនៅក្នុង រយៈចំហរ ។ រយៈចំហរ ជារយៈពេលដែលមនុស្សម្នាក់បានឆ្លងមេរោគអេដស៍ ប៉ុន្តែរាងកាយរបស់គេមិនទាន់បានបង្កើតអង្គបដិបក្ខប្រាណនៅឡើយ។ ប្រសិនបើអ្នកគិតថា អ្នកបានឆ្លងមេរោគអេដស៍ក្នុងអំឡុងពេល៣ខែចុងក្រោយ អ្នកគួរតែធ្វើតេស្តរកមេរោគអេដស៍ម្តងទៀតក្នុងអំឡុងពេល៣ខែក្រោយបន្ទាប់ពីមានការប្រព្រឹត្តប្រឈមណាមួយ។ប្រសិនបើអ្នកបន្តការប្រព្រឹត្តប្រឈម ដែលអាចធ្វើឱ្យអ្នកមានហានិភ័យប្រឈមនឹងការឆ្លងមេរោគអេដស៍អ្នកគួរតែធ្វើតេស្តឲ្យបានជាប្រចាំ។
10. ***តើលទ្ធផលតេស្តវិជ្ជមានមានន័យយ៉ាងដូចម្តេច ?***
    លទ្ធផលតេស្តវិជ្ជមានមានន័យថា អ្នកអាចមានផ្ទុកមេរោគអេដស៍ ។ ការធ្វើតេស្តបន្ថែមទៀត ត្រូវតែធ្វើនៅនៅឯមណ្ឌលសុខភាពដើម្បីបញ្ជាក់ពីលទ្ធផលតេស្ត។
11. ***តើខ្ញុំគួរធ្វើដូចម្តេចប្រសិនបើខ្ញុំទទួលបានលទ្ធផលតេស្តវិជ្ជមាន ?***
    អ្នកត្រូវទៅសេវាសុខភាពដើម្បីធ្វើតេស្តបញ្ជាក់ពីលទ្ធផលតេស្ត។ កំឡុងពេលនេះសេវាសុខភាពក្នុងតំបន់របស់អ្នក គ្រូពេទ្យ វេជ្ជបណ្ឌិត អ្នកផ្តល់សេវាសុខភាព នឹងពិភាក្សាពីជំហានដែលត្រូវធ្វើបន្ទាប់ទៀត។
12. ***តើខ្ញុំអាចទទួលបានលទ្ធផល តេស្តអវិជ្ជមានអវិជ្ជមាន មិនពិត (មិនត្រឹមត្រូវ) ក្នុងការធ្វើតេស្តនេះដែរឬទេ***
    លទ្ធផលតេស្ត អវិជ្ជមាន មិនពិត អាចនឹងកើតមានឡើងដោយហេតុផលដូចខាងក្រោម៖
    - ប្រសិនបើអ្នកបានប្រព្រឹត្តប្រឈមតិចជាង៣ខែ មុនពេលធ្វើតេស្ត
    - មើលលទ្ធផលតេស្តមិនត្រឹមត្រូវ ដោយថាជាលទ្ធផលតេស្តអវិជ្ជមាន
    - មិនអនុវត្តតាមការណែនាំពីរបៀបធ្វើតេស្តដោយប្រុងប្រយ័ត្ន
    - ប្រសិនបើអ្នកអូសឧបករណ៍តេស្តពីលើធ្មេញពាក់ ឬឧបករណ៍ផ្សេងៗទៀតដែលគ្របពីលើអញ្ចាញធ្មេញរបស់អ្នក
    - ប្រសិនបើអ្នកកំពុងប្រើប្រាស់ឱសថបង្ការមុនពេលប្រឈមនឹងការឆ្លងមេ**រោគ អេដស៍** PrEP ឬ កំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ARV)
13. ***តើខ្ញុំអាចទទួលបានលទ្ធផលវិជ្ជមាន មិនពិត (មិនត្រឹមត្រូវ) ក្នុងការធ្វើតេស្តនេះដែរឬទេ ?***
    លទ្ធផលវិជ្ជមានមិនពិត (ខុស) អាចកើតមានឡើងដោយសារហេតុផលដូចខាងក្រោម៖
    - មើលលទ្ធផលតេស្តមិនត្រឹមត្រូវថាជាតេស្តវិជ្ជមាន
    - មិនធ្វើតាមការណែនាំដោយប្រុងប្រយ័ត្នពីរបៀបប្រើប្រាស់តេស្ត
    - មិនរង់ចាំ ១៥ នាទីបន្ទាប់ពីពិសារ ឬផឹកទឹកអ្វី ឬ ៣០ នាទីបន្ទាប់ពីប្រើផលិតផលថែរក្សាមាត់ មុនពេលធ្វើតេស្ត
    - បានទទួលការចាក់វ៉ាក់សាំងការពារមេរោគអេដស៍
    - អូសឧបករណ៍តេស្តតាមអញ្ចាញធ្មេញលើ និងក្រោមច្រើនដងពេកក្នុងពេលប្រមូលទឹកមាត់
14. ***តើកន្លែងណាដែលខ្ញុំអាចទទួលបានការជួយគាំទ្រ ឬការថែទាំជំងឺអេដស៍ ?***
    អ្នកអាចទទួលបានការជួយបន្ថែមតាមរយៈ គ្លីនិកក្នុងតំបន់ វេជ្ជបណ្ឌិត ឬ អ្នកឯកទេសថែទាំសុខភាព។
15. ***តើខ្ញុំអាចធ្វើតេស្តនេះបានទេ ប្រសិនបើខ្ញុំកំពុងប្រើប្រាស់ឱសថបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (oral PrEP) ?***
    ប្រសិនបើអ្នកកំពុងប្រើប្រាស់ឱសថបង្ការមុនពេលប្រឈមនឹងការឆ្លងមេរោគអេដស៍ PrEP លទ្ធផលតេស្តរបស់អ្នកអាចនឹងមិនត្រឹមត្រូវ។
16. ***តើខ្ញុំអាចដឹងថា ការធ្វើតេស្តរបស់ខ្ញុំមានដំណើរការត្រឹមត្រូវបានដោយរបៀបណា ?***
    ប្រសិនបើតេស្តរបស់អ្នកដំណើរការបានត្រឹមត្រូវ អ្នកនឹងឃើញមានបន្ទាត់ឆ្នូតលេចឡើងនៅចំណុច "C" នៅលើឧបករណ៍តេស្តរបស់អ្នក។ ប្រសិនបើគ្មានបន្ទាត់ឆ្នូតនៅជាប់ចំណុច "C" ទេ នោះតេស្តរបស់អ្នកគឺមិនដំណើរការឡើយ។
17. ***តើខ្ញុំអាចប្រើតេស្តនេះបានដែរឬទេ ប្រសិនបើខ្ញុំមានផ្ទៃពោះ ?***
    ប្រើបាន ប្រសិនបើអ្នកមានផ្ទៃពោះ អ្នកអាចធ្វើតេស្តបានគ្រប់ពេលវេលា។

### សារធាតុរំខាន និង លក្ខណៈដែលមិនទាក់ទងនឹងវេជ្ជសាស្រ្ត

ផ្នែកមួយនៃការសិក្សាក្នុងសារធាតុរាវក្នុងមាត់ ព័ត៌មានត្រូវបានប្រមូលពីអ្នកចូលរួមដែលកំពុងមានជំងឺ និងស្ថានភាពវេជ្ជសាស្រ្តនៅក្នុងកំឡុងពេលធ្វើតេស្ត ជំងឺមាត់ មេរោគឆ្លងផ្សេងៗដែលមិនមែនជាមេរោគអេដស៍ និងកត្តាផ្សេងៗទៀត (ឧ. ការប្រើប្រាស់ថ្នាំជក់ ខ្ពុរមាត់ក្នុងរង្វង់ ២៤ម៉ោងនៃការធ្វើតេស្ត ការប្រើប្រាស់ថ្នាំនៅក្នុងពេលធ្វើតេស្ត ការព្យាបាលធ្មេញ និងពិសារអាហារ ឬផឹកទឹកអ្វីភ្លាមៗមុនពេលធ្វើ តេស្ត) ។ នៅក្នុងការសិក្សាដាច់ដោយឡែកមួយទៀតជាមួយមនុស្ស ៤០ នាក់ ដែលផឹកគ្រឿងស្រវឹង ដុសធ្មេញ ខ្ពុរមាត់ ឬជក់បារី ៥ នាទីក្នុងកំឡុងពេលធ្វើតេស្តបានបង្ហាញថាគ្មានផលប៉ះពាល់ដល់ភាពជាក់លាក់នៃតេស្តនោះទេ។ មានការណែនាំដល់អ្នកប្រើប្រាស់តេស្ត គួររង់ចាំ ១៥ នាទី ក្រោយពីពិសារអាហារឬ ផឹកទឹកអ្វី ឬ ៣០ នាទី ក្រោយពីការពីប្រើផលិតផលថែរក្សាមាត់។ **ប្រសិនបើអ្នកមានមេរោគរលាកថ្លើមប្រភេទ បេ សេ ឬ មានផ្ទុកមេរោ** HTLV I/II **នោះលទ្ធផលតេស្តអ្នកអាចនឹងមិនត្រឹមត្រូវ។**

## ការពន្យល់អំពីនិមិត្តសញ្ញា

| | | | | | | | |
|---|---|---|---|---|---|---|---|
| LOT | បាកូដ | REF | លេខកាតាឡុក | ⚠ | ការប្រុងប្រយ័ត្ន ពិគ្រោះយោបល់ ឯកសារដែលភ្ជាប់មកជាមួយ | i | ពិគ្រោះ អំពីការណែនាំពីរបៀបប្រើប្រាស់ |
| ⊗ | ហាមប្រើម្តងទៀត | IVD | ឧបករណ៍ធ្វើរោគវិនិច្ឆ័យវេជ្ជសាស្រ្ត | | ក្រុមហ៊ុនផលិត | EXP | កាលបរិច្ឆេទផុតកំណត់ |
| | ការកំណត់សីតុណ្ហភាព | | រយៈពេលប្រើ | | | DOM | កាលបរិច្ឆេទផលិត |

**ផលិតនៅប្រទេសថៃ**


OraSure Technologies, Inc.
220 East First Street,
Bethlehem, PA 18015 USA
(+1) 610-882-1820
www.OraSure.com


©2018 OraSure Technologies, Inc. • OraQuick®, ការរចនាឡូហ្គូ និងសញ្ញាពាណិជ្ជកម្មនៃ OraSure Technologies, Inc.

ទំនិញលេខ# 3001-3100 rev. 01/18